-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៦/០៨ ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០៦ ខែ មិថុនា ឆ្នាំ ២០០០

### ត្រាស់បង្គាប់

មាត្រា ១ .- ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូនវរសេនីយ៍ឯក សោ រិនី ប្រធាននាយកដ្ឋាន នគរបាលសេដ្ឋកិច្ច នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ .- បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

***

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៣១ អនក្រ.បក

### ស្តីពី

### ការបង្កើតស្រុកគាស់ក្រឡចំណុះខេត្តបាត់ដំបង

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

www.pheakdeylaw.com

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា ១ .- ត្រូវបានបង្កើតស្រុកកោះក្រឡ ដោយកាត់យកភូមិភាគត្បូងមួយចំណែកពីស្រុកមោងឫស្សី ។

មាត្រា ២ .- ស្រុកកោះក្រឡ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តបាត់ដំបង ។

មាត្រា ៣ .- ស្រុកកោះក្រឡ ត្រូវបានបង្កើតឃុំចំនួន ០៦ គឺឃុំធិបតី ឃុំកោះក្រឡ ឃុំហប់ ឃុំដូនបា ឃុំព្រះផុស និងឃុំឆ្នាល់មាន់ ។

មាត្រា ៤ .- ស្រុកកោះក្រឡ ត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាល ដូចខាងក្រោម :

-ខាងជើង ទល់នឹងស្រុកបាណន់ និង ស្រុកសង្កែ ខេត្តបាត់ដំបង ។

-ខាងត្បូង ទល់នឹងស្រុកវាលវែង ខេត្ត ពោធិ៍សាត់ ។

-ខាងកើត ទល់នឹងស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

-ខាងលិច ទល់នឹងស្រុកសំឡូត និង ស្រុកបាណន់ ខេត្តបាត់ដំបង ។

មាត្រា ៥ .- ទីតាំងស្នាក់ការស្រុកកោះក្រឡ ស្ថិតនៅក្នុងឃុំកោះក្រឡ ។

មាត្រា ៦ .- បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យ លេខ ៣២ អនក្រ.បក**

**ស្ដីពី**

**វិសោធនកម្មមាត្រា ១៤ និង ១៥ នៃអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី២៧ ខែ មីនា ឆ្នាំ ១៩៩៦ ស្ដីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា